# ពិធីសារសម្រាប់ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 នៅក្នុងវិទ្យាស្ថានឧត្តមសិក្សានានា៖ ឧបសម្ព័ន្ធ Y2

សំគាល់: ឯកសារពិធីសារនេះ ត្រូវបានបង្កើតឡើងដោយមិនមានអត្ថប្រយោជន៍ នៃការណែនាំ CDPH ដែលនឹងមកដល់ ដែលជាក់លាក់ចំពោះតែវិទ្យាស្ថានឧត្តមសិក្សាប៉ុណ្ណោះ។ នៅពេលមានការណែនាំពី CDPH, ឯកសារនេះ ប្រហែលជាត្រូវធ្វើការផ្លាស់ប្តូរ ដើម្បីធានានូវភាពស៊ីសង្វាក់គ្នា រវាងរដ្ឋ និងខោនធី។

ការឆ្លើយតបសុខភាពសាធារណៈជាគោលដៅ ដើម្បីគ្រប់គ្រងការប្រឈម/ប៉ះពាល់ជំងឺ COVID-19 នៅកម្រិតសហគមន៍ អាចជួយបង្កើនឥទ្ធិពល ឬផលប៉ះពាល់ នៃការឆ្លើយតបទៅនឹងជំងឺ COVID-19 នៃនាយកដ្ឋានសុខភាពសាធារណៈខោនធីឡូសអានចែលឡេស (DPH)។

IHE គឺជាដៃគូសហគមន៍ដែលអាចជឿទុកចិត្តបាន ដែលអាចជួយ DPH ធ្វើអោយទាន់ពេលវេលា និងផលប៉ះពាល់នៃការឆ្លើយតបសុខភាពសាធារណៈ តាមរយៈការផ្តួចផ្តើមផែនការគ្រប់គ្រងការប្រឈមជំងឺ COVID-19 (EMP) របស់ IHE នៅពេលមានការផ្តល់ដំណឹងអំពីករណីជំងឺ COVID-19 និងបណ្តុំ/ចង្កោមនៃជំងឺនៅបរិវេណសាលារៀន។ ការអនុវត្ត EMP ជាបន្ទាន់ នៅពេលដែលករណីតែមួយនៃជំងឺ COVID-19 ត្រូវបានកំណត់ឃើញ នៅ IHE មួយ អាចបង្កើននូវសមត្ថភាពគ្រប់គ្រងការរីករាលដាលនៃការឆ្លង និងបង្ការការផ្ទុះឡើង ឬរាតត្បាត នៅបរិវេណសាលារៀន ពីការកើតឡើងបាន។

ជំហ៊ានសំរាប់ការគ្រប់គ្រងការប្រឈម/ប៉ះពាល់ នៃជំងឺ COVID-19 ករណីទី ១, ទី ២, និងទី ៣ ឬច្រើនជាងនេះ នៅបរិវេណសាលារៀន ត្រូវបានពិពណ៌នាដូចខាងក្រោម និងសង្ខេបនៅក្នុងតារាង A។ ដោយសារ IHE និងមានភាពខុសគ្នា នៅក្នុងកម្រិតនៃធនធានសម្រាប់ការគ្រប់គ្រងការប្រឈមជំងឺ COVID-19, ជំហ៊ាននានា*ដែលចាំបាច់ធ្វើ ឬត្រូវធ្វើ* គឺជាធាតុអប្បបរមា ដែលគួរតែត្រូវបានរាប់បញ្ចូលក្នុង EMP។ ជំហ៊ាននានា*ដែលបានណែនាំអោយធ្វើ* រួមមានធាតុសម្រាប់ការគ្រប់គ្រងតាមមូលដ្ឋាននៃការប្រឈម ដែលធនធាន IHE មានគ្រប់គ្រាន់។

ពាក្យ "ទីធ្លា ឬបរិវេណ" នៅក្នុងឯកសារនេះសំដៅទៅលើកន្លែងមិនមែនជាលំនៅដ្ឋាន នៅលើទ្រព្យសម្បត្តិរបស់ IHE និងកន្លែងប្រមូលផ្តុំលំនៅដ្ឋាន ដែលអោយរស់នៅ ឬជួលក្រុមនិស្សិត និងនិយោជិកក្រុមធំៗ នៃ IHE ទាំងនៅក្នុង និងក្រៅបរិវេណសាលា។

## ការរៀបចំផែនការគ្រប់គ្រងការប្រឈម មុនពេលកំណត់ឃើញ ១ ករណី នៃជំងឺ COVID-19 នៅកន្លែង IHE

☐ ***ចាំបាច់ធ្វើ:*** ក្រុមការងារអនុលោមតាមជំងឺ IHE COVID-19 ដែលបានត្រូវចាត់តាំងរបស់សាលារៀន ដែលទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តនូវរាល់ពិធីសារសុវត្ថិភាពជំងឺ COVID-19 និងធានាថាបុគ្គលិក និងនិសិត្ស ទទួលបានការ

អប់រំ អំពីជំងឺ COVID-19។ មន្ត្រីអនុលោមតាមច្បាប់ជំងឺ COVID-19 ដែលបានត្រូវចាត់តាំង ជាអ្នកនាំពាក្យទៅកាន់ DPH ក្នុងករណីមានបណ្តុំ/ចង្កោម ឬការផ្ទុះឡើងនៃជំងឺ COVID-19 នៅឯកន្លែង ឬគ្រឹះស្ថាន IHE។

☐ ***តំរូវការ:***ការផ្តត់ផ្គង់លំនៅដ្ឋានអោយបានគ្រប់គ្រាន់សំរាប់និស្សិត និងការរស់នៅក្នុងបរិវេណមហាវិទ្យាល័យ ដើម្បីដាក់ខ្លួនអោយនៅឯកោ ឬធ្វើចត្តាឡីស័កដោយសុវត្ថិភាព នៅពេលមានតម្រូវការ។

☐ ***ចាំបាច់ធ្វើ:*** ផែនការសម្រាប់និស្សិត និងនិយោជិកទាំងអស់ ដែលមានរោគសញ្ញាផ្សេងៗសមស្រប ឬស៊ីសង្វាក់នឹងជំងឺ COVID-19 ឬត្រូវបានដាក់អោយធ្វើចត្តាឡីស័ក ដោយសារតែការប្រឈម/ប៉ះពាល់នឹងករណី (ច្រើន) នៅបរិវេណសាលារៀន ដើម្បីទទួលបានការធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សម្រាប់ជំងឺ COVID-19។

## ការគ្រប់គ្រងការប្រឈមជំងឺ COVID-19 ដែលមាន ១ ករណី នៅកន្លែង IHE

☐ ***ចាំបាច់ធ្វើ:*** បន្ទាប់ពីកំណត់ឃើញពីមន្ទីរពិសោធន៍ ដែលបានបញ្ជាក់អំពីជំងឺ COVID-19 ចំនួន ១ ករណី (និស្សិត ឬនិយោជិក), ក្រុមការងារអនុលោមតាមរបស់ IHE ស្នើសុំអោយករណីនោះ អនុវត្តតាម សេចក្តីណែនាំអំពីការដាក់ខ្លួនឯងអោយនៅឯកោនៅផ្ទះសំរាប់ជំងឺ COVID-19។

☐ ***ចាំបាច់ធ្វើ:*** ក្រុមការងារអនុលោមតាមរបស់ IHE ចេញ បទបញ្ជាមន្ត្រីសុខាភិបាលសម្រាប់ដាក់ករណីអោយនៅឯកោ ទៅកាន់ករណីនេះ។

☐ ***ចាំបាច់ធ្វើ:*** ក្រុមការងារអនុលោមតាមរបស់ IHE ធ្វើការជាមួយករណី ដើម្បីបង្កើតបញ្ជីឈ្មោះនិស្សិត និង/ឬនិយោជិក ដែលមានការប្រឈម/ប៉ះពាល់នឹងករណីនេះ ក្នុងកំឡុងពេលឆ្លង។ មន្ត្រីអនុតាមតាមរបស់ IHE ផ្តល់នូវព័ត៌មាននេះទៅអោយ នាយកដ្ឋានសុខាភិបាលឡុងប៊ីច ដោយប្រើនូវ ឯ: ករណីជំងឺ COVID-19 និងបញ្ជីខ្សែស្រឡាយទំនាក់ទំនង សម្រាប់វិស័យអប់រំ ក្នុងរយៈពេលមួយថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានជូនដំណឹងអំពីករណីដែលបានបញ្ជាក់។ សម្រាប់ជំនួយបច្ចេកទេស ស្តីពីវិធីបំពេញបញ្ជីទំនាក់ទំនងខ្សែស្រឡាយ: COVID19Edu@longbeach.gov

- ករណីមួយ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលរោគសញ្ញានានារបស់ពួកគេ លេចចេញមកជាលើកដំបូង រហូតដល់ពេលដែលពួកគេមិនត្រូវបានដាក់អោយនៅដាច់ឆ្ងាយឯកោ (មានន័យថា, មិនគ្រុនក្តៅ យ៉ាងហោចណាស់រយៈពេល ២៤ ម៉ោង, ដោយមិនប្រើថ្នាំដែលបន្ថយគ្រុនក្តៅ **និង** រោគសញ្ញានានាបានប្រសើរឡើង **និង** យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញឡើងដំបូង) ។ មនុស្សម្នាក់ដែលតេស្តជំងឺ COVID-19 ឃើញមានវិជ្ជមាន ប៉ុន្តែមិនមានរោគសញ្ញាអ្វីនោះទេ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលការធ្វើតេស្តរបស់ពួកគេ ត្រូវបានធ្វើឡើង រហូតដល់ ១០ ថ្ងៃ ក្រោយពីការធ្វើតេស្តរបស់ពួកគេ។
- មនុស្សម្នាក់ ត្រូវបានគេចាត់ទុកថាបានប្រឈម ប្រសិនបើពួកគេ ជាមនុស្សម្នាក់ ដូចខាងក្រោម:
  - បុគ្គលដែលបានស្ថិតក្នុងចម្ងាយ ៦ ហ្វីត នៃអ្នកដែលបានឆ្លងជំងឺនេះ អស់រយៈពេលច្រើនជាង ១៥ នាទី, បើទោះបីជាមានការពាក់គម្របមុខ មិនមែនជាគម្របមុខវេជ្ជសាស្ត្រ ក៏ដោយ;

- បុគ្គលដែលមានទំនាក់ទំនងដោយមិនបានការពារ ជាមួយនឹងវត្ថុរាវរាងកាយ និង/ឬទឹករំអិលរបស់មនុស្សម្នាក់ ដែលមានការបញ្ជាក់ថា ឬមានការសង្ស័យថា មានជំងឺ COVID-19 (ឧទាហរណ៍ ត្រូវបានគេក្អកដាក់ ឬកណ្ដាស់ដាក់, ចែករំលែកប្រដាប់ប្រដាប្រើប្រាស់ ឬទឹកមាត់, ឬផ្ដល់នូវការថែទាំ ដោយមិនប្រើឧបករណ៍ការពារសមស្រប)។

☐ ***ចាំបាច់ធ្វើ:*** និស្សិត និងនិយោជិក ដែលត្រូវបានគេកំណត់អត្តសញ្ញាណថាមានការប្រឈម/ប៉ះពាល់ទៅនឹងករណី ត្រូវបានជូនដំណឹងដោយក្រុមការងារអនុលោមរបស់ IHE តាមរយៈលិខិតមួយច្បាប់ ឬយុទ្ធសាស្ត្រទំនាក់ទំនងផ្សេងទៀត។ គំរូលិខិតជូនដំណឹង អំពីការប្រឈម/ប៉ះពាល់នៅឬក្នុងបរិវេណសាលា មាននៅឯ: គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19។ ការជូនដំណឹងគួរតែមានរួមបញ្ចូលនូវសារនានា ដូចខាងក្រោម:

- និស្សិត និងនិយោជិកដែលប្រឈមទៅនឹងករណី នៅក្នុងបរិវេណសាលាគួរតែធ្វើតេស្តរកមើលជំងឺ COVID-19, ទោះបីពួកគេមានរោគសញ្ញា ឬអត់, ហើយជូនដំណឹងដល់ IHE អំពីលទ្ធផលនៃការធ្វើតេស្ត។ នេះនឹងកំណត់វិសាលភាពនៃការរីករាលដាលនៃជំងឺនៅតាមបរិវេណសាលា និងធ្វើជាមូលដ្ឋានសម្រាប់វិធានការណ៍ត្រួតពិនិត្យបន្តទៀត។ ធនធានសម្រាប់ការធ្វើតេស្ត រួមបញ្ចូលនូវ: សេវាកម្មសុខភាពនិយោជិក ឬសេវាកម្មសុខភាពវិជ្ជាជីវៈ, មជ្ឈមណ្ឌលសុខភាពនិស្សិត, អ្នកផ្ដល់សេវាថែទាំសុខភាពផ្ទាល់ខ្លួន, កន្លែងធ្វើតេស្តសហគមន៍។ បុគ្គលដែលត្រូវការជំនួយ ក្នុងការស្វែងរកអ្នកផ្ដល់សេវាវេជ្ជសាស្ត្រ អាចទូរស័ព្ទទៅកម្មវិធីផ្សព្វផ្សាយមេឌីខាល តាមលេខ ៥៦២.៥៧០.៧៩៧៩។
- និស្សិត និងនិយោជិក ដែលមានការប្រឈម/ប៉ះពាល់ ត្រូវតែធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ ចាប់តាំងពីការប្រឈមចុងក្រោយទៅនឹងករណី ខណៈពេលឆ្លង (ដូចបានកំណត់ខាងលើ), ទោះបីជាពួកគេទទួលបានលទ្ធផលតេស្តអវិជ្ជមាន ក្នុងកំឡុងពេលនៃការធ្វើចត្តាឡីស័ក ក៏ដោយ។ មនុស្សម្នាក់ដែលធ្វើតេស្តឃើញអវិជ្ជមាន អាចនឹងវិវត្តន៍ទៅជាជំងឺជាបន្តបន្ទាប់, ដែលមាន ឬគ្មានរោគសញ្ញា, ប្រសិនបើត្រូវបានធ្វើតេស្ត ក្នុងអំឡុងពេលភ្ញាស់/មេរោគសំងំក្នុងខ្លួន (ពោលគឺ រយៈពេលរវាងការប្រឈម/ប៉ះពាល់ នឹងការចាប់ផ្ដើមជំងឺ)។ ការណែនាំ សម្រាប់ការធ្វើចត្តាឡីស័កនៅផ្ទះ សំរាប់ជំងឺ COVID-19 មាននៅ: http://longbeach.gov/globalassets/health/media-library/documents/diseases-and-condition/information-on/novel-coronavirus/general-public-handouts-and-graphics/covhomequarantine
- IHE នឹងជួយកំណត់អត្តសញ្ញាណគេហដ្ឋានសម្រាប់និស្សិត និងមហាវិទ្យាល័យ ដែលកំពុងរស់នៅក្នុងបរិវេណសាលា ដើម្បីដាក់ខ្លួនអោយនៅឯកោ ឬធ្វើចត្តាឡីស័កដោយសុវត្ថិភាព នៅពេលដែលមានតំរូវការ។
- IHE នឹងទាក់ទងនិស្សិត និងនិយោជិកដែលមានការប្រឈម/ប៉ះពាល់ ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញនូវបទបញ្ជាមន្ត្រីសុខាភិបាលសម្រាប់ការធ្វើចត្តាឡីស័ក។

- ***ណែនាំអោយធ្វើ:*** ក្រុមការងារអនុលោមតាម របស់ IHE នឹងកំណត់ថាតើចាំបាច់ត្រូវមានការជូនដំណឹងបន្ថែម ដើម្បីជូនដំណឹងដល់សហគមន៍បរិវេណសាលារៀន អោយបានទូលំទូលាយជាងមុន អំពីការប្រឈម/ប៉ះពាល់ និងការប្រុងប្រយ័ត្ន ដែលត្រូវបានធ្វើឡើង ដើម្បីការពារការរីករាលដាលនៃជំងឺ COVID-19។ គំរូលិខិតជូនដំណឹងទូទៅ មាននៅឯ: គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19។

## ការគ្រប់គ្រងការប្រឈមជំងឺ COVID-19 ដែលមាន ២ ករណី ក្នុងរយៈពេល ១៤ ថ្ងៃ នៅកន្លែង IHE

☐ ***ចាំបាច់ធ្វើ:*** បន្ទាប់ពីកំណត់ឃើញពីមន្ទីរពិសោធន៍ អំពីករណីដែលបានបញ្ជាក់ ចំនួន ២ ករណី (និស្សិត និង/ឬនិយោជិក) ក្នុងរយៈពេល ១៤ ថ្ងៃ, IHE អនុវត្តតាមជំហ៊ានចាំបាច់នានា សម្រាប់ករណីដែលបានបញ្ជាក់ ១ ករណី។

☐ ***ណែនាំអោយធ្វើ៖*** ក្រុមការងារអនុលោមតាមរបស់ IHE ប៉ាន់ប្រមាណ ថាតើករណីដែលបានបញ្ជាក់ ចំនួន ២ ករណី មាន ទំនាក់ទំនង ឬតំណរភ្ជាប់នឹងរោគរាតត្បាតដែរឬទេ, មានន័យថា បុគ្គលដែលបានឆ្លងទាំងពីរនាក់ ជាចំណុចរួម មានវត្តមាន នៅកន្លែង និងពេលវេលាតែមួយ ក្នុងកំឡុងពេលដែលពួកគេបានឆ្លង។*

* *ករណីមួយ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលមានរោគសញ្ញានានា លេចចេញមកជាលើកដំបូង រហូតដល់ពេលដែលពួកគេ មិនត្រូវបានដាក់អោយនៅឯកោទៀតឡើយ (មានន័យថា, មិនគ្រុនក្តៅ យ៉ាងហោចណាស់រយៈពេល ២៤ ម៉ោង, ដោយមិនប្រើថ្នាំដែលបន្ថយគ្រុនក្តៅ **និង** រោគសញ្ញានានាបានប្រសើរឡើង **និង** យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញឡើងដំបូង)។ មនុស្សម្នាក់ដែលតេស្តជំងឺ COVID-19 ឃើញមានវិជ្ជមាន ប៉ុន្តែមិនមានរោគសញ្ញាណាអ្វីនោះទេ ត្រូវបានគេចាត់ទុកថាឆ្លងពី ២ ថ្ងៃ មុនពេលការធ្វើតេស្តរបស់ពួកគេ ត្រូវបានធ្វើឡើងរហូតដល់ ១០ ថ្ងៃក្រោយ ពីការធ្វើតេស្តរបស់ពួកគេ។*

- ការកំណត់នូវទំនាក់ទំនង ឬតំណរភ្ជាប់នៃរោគរាតត្បាត រវាងករណីនានា អាចតម្រូវអោយមានការស៊ើបអង្កេតបន្ថែមទៀត ដើម្បីស្វែងយល់ពីប្រវត្តិនៃការប្រឈម/ប៉ះពាល់ និងកំណត់នូវទីតាំង និងមនុស្សទាំងអស់ ដែលអាចត្រូវបានប្រឈមនឹងករណីនេះ នៅខណៈពេលឆ្លង។ ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។ សម្រាប់ជំនួយបច្ចេកទេសស្តីពីវិធីវាយតម្លៃទំនាក់ទំនង ឬតំណរភ្ជាប់នឹងរោគរាតត្បាត, សូមទាក់ទង COVID19Edu@longbeach.gov។

## ការគ្រប់គ្រងការប្រឈមជំងឺ COVID-19 ដែលមាន ≥ ៣ ករណី ក្នុងរយៈពេល ១៤ ថ្ងៃ នៅកន្លែង IHE

☐ ***ចាំបាច់ធ្វើ:*** ប្រសិនបើ IHE កំណត់ឃើញពីមន្ទីរពិសោធន៍ អំពីបណ្តុំ/ចង្កោមនៃករណីដែលបានបញ្ជាក់ ចំនួន ៣ ករណី ឬច្រើនជាងនេះ (និស្សិត និង/ឬនិយោជិក) ក្នុងរយៈពេល ១៤ ថ្ងៃ, IHE ត្រូវតែដំណើរការនូវជំហ៊ាននានា ដូចខាងក្រោម:

- រាយការណ៍អំពីចង្កោមទៅកាន់កម្មវិធីត្រួតពិនិត្យជំងឺឆ្លង របស់នាយកដ្ឋានសុខាភិបាលឡុងប៊ីច ក្នុងរយៈពេល ១ ថ្ងៃ នៃថ្ងៃធ្វើការ នៃការជូនដំណឹងអំពីចង្កោមនេះ ទៅលេខ ៥៦២.៥៧០.៤៣០២។
- បំពេញបញ្ជីរាយខ្សែស្រឡាយសម្រាប់ករណី និងទំនាក់ទំនងទាំងឡាយ, រកបាន ឬមានមាននៅ: ករណី COVID-19 និងបញ្ជីទំនាក់ទំនងខ្សែស្រឡាយ សម្រាប់វិស័យអប់រំ ហើយបញ្ជូនទៅកាន់ COVID19Edu@longbeach.gov។

- ក្រុមជំងឺ COVID-19 សាលារៀន របស់នាយកដ្ឋានសុខាភិបាល និងពិនិត្យបញ្ជីខ្សែស្រឡាយករណី និងទំនាក់ទំនងទាំងឡាយ ដើម្បីកំណត់ថាតើ ការផ្ទុះឡើងត្រូវបានបំពេញ/សមស្របតាមលក្ខណៈវិនិច្ឆ័យ ឬអត់។
- ប្រសិនបើវាត្រូវបានគេកំណត់ថា លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង មិនត្រូវបានបំពេញ/សមស្របនោះទេ, បន្តការត្រួតពិនិត្យជាប្រចាំ អំពីការប្រឈម/ប៉ះពាល់នៃជំងឺ COVID-19។
- ប្រសិនបើវាត្រូវបានកំណត់ថា លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង ត្រូវបានបំពេញ/សមស្រប, នាយកដ្ឋានសុខាភិបាល និងពិគ្រោះយោបល់ជាមួយសាលារៀន ស្តីអំពីការស៊ើបអង្កេត និងការគ្រប់គ្រងនូវការផ្ទុះឡើងនោះ។
- ក្រុមការងារអនុលោមសាលារៀន និងបញ្ជូនព័ត៌មានដែលបានស្នើសុំ, រួមទាំងព័ត៌មានថ្មីៗ/ទាន់សម័យ បញ្ជីរាយខ្សែស្រឡាយអប់រំសម្រាប់ករណី និងទំនាក់ទំនងទាំងឡាយ ទៅកាន់នាយកដ្ឋានសុខាភិបាល រហូតដល់ការផ្ទុះឡើងត្រូវបានដោះស្រាយ (យ៉ាងហោចណាស់ ១៤ ថ្ងៃ ចាប់តាំងពីករណីដែលបានបញ្ជាក់ចុងក្រោយ)។

□ ***ណែនាំអោយធ្វើ៖*** មុនពេលរាយការណ៍អំពីចង្កោម, ក្រុមការងារអនុលោមសាលារៀន និងវាយតម្លៃថាតើមានយ៉ាងហោចណាស់ ៣ ករណី នៅក្នុងចង្កោមនេះ មានទំនាក់ទំនង ឬតំណរភ្ជាប់នឹងរោគរាតត្បាត ដែរឬទេ។ ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។

## លក្ខណៈវិនិច្ឆ័យ នៃការផ្ទុះឡើងជំងឺ COVID-19 សំរាប់វិទ្យាស្ថានឧត្តមសិក្សា

<u>កន្លែងមិនមែនជាលំនៅដ្ឋាន IHE:</u> យ៉ាងហោចណាស់ មានការបញ្ជាក់ពីមន្ទីរពិសោធន៍ ចំនួន ៣ ករណី ដែលបង្ហាញរោគសញ្ញានានា ឬមិនមានបង្ហាញនូវរោគសញ្ញានានា នៃជំងឺ COVID-19 ឡើយ ក្នុងរយៈពេល ១៤ ថ្ងៃ នៅក្នុងក្រុម IHE មួយ ដែលមានទំនាក់ទំនងនឹងរោគរាតត្បាត។*

* *ក្រុម IHE រួមបញ្ចូលនូវមនុស្សនានា ដែលចែករំលែកសមាជិកភាពទូទៅ (ដូចជា ក្រិក/កន្លែងជុំគ្នា ឬអង្គការអង្គការសង្គមផ្សេងៗ, ក្រុមអត្តពលកម្ម, ក្លឹបកីឡានិងក្លឹបកំសាន្ត, ក្រុមអប់រំសិក្សា, កន្លែងធ្វើការនៅតាមបរិវេណសាលា)។ ទំនាក់ទំនង ឬតំណរភ្ជាប់នឹងរោគរាតត្បាត តំរូវថា បុគ្គលនានាដែលបានឆ្លង ជាចំណុចរួម មានវត្តមាននៅកន្លែង និងពេលវេលាតែមួយ ក្នុងកំឡុងពេលដែលបានឆ្លង។*

<u>កន្លែងលំនៅដ្ឋាន IHE:</u> យ៉ាងហោចណាស់ មានការបញ្ជាក់ពីមន្ទីរពិសោធន៍ ចំនួន ៣ ករណី ដែលបង្ហាញរោគសញ្ញានានា ឬមិនមានបង្ហាញនូវរោគសញ្ញានានា នៃជំងឺ COVID-19 ឡើយ ក្នុងរយៈពេល ១៤ ថ្ងៃ នៅក្នុងលំនៅដ្ឋានតែមួយ ឬច្រើន ដែលចែករំលែក តំបន់រួម។

* *កន្លែងលំនៅដ្ឋាន IHE រួមមានទាំង កន្លែងហៅស៊ីងលំនៅដ្ឋាន នៅលើ/ក្នុង - និងក្រៅបរិវេណសាលា ដែលក្រុមនិស្សិត IHE និង/ឬ និយោជិកប្រមូលផ្តុំ និង/ឬរស់នៅ (ឧទាហរណ៍ ទីលំនៅនៅក្នុងបរិវេណសាលា, ហៅស៊ីងក្រិកនៅលើ/ក្នុង - ឬក្រៅបរិវេណ)។*

**ឧបសម្ព័ន្ធ A: ជំហ៊ាននានា សំរាប់ការគ្រប់គ្រងការប្រឈម/ប៉ះពាល់ករណី ១, ២ និង ≥ ៣ នៃករណីរជំងឺ COVID-19 ដែលបានបញ្ជាក់ ក្នុងកន្លែងប្រមូលផ្តុំគ្នា ដែលមិនមែនជាលំនៅដ្ឋាន ឬលំនៅដ្ឋាន ដែលជាប់ទាក់ទងជាមួយ IHE**

| | |
|---|---|
| **1 ករណី** | 1) *ចាំបាច់ធ្វើ:* IHE ណែនាំអោយករណី អនុវត្តតាមសេចក្តីណែនាំដាក់ខ្លួនអោយនៅឯកោ (a)<br>2) *ចាំបាច់ធ្វើ:* IHE ប្រាប់ករណីថា DPH នឹងទាក់ទងជាមួយករណីដោយផ្ទាល់ ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញបទបញ្ជាមន្ត្រីសុខភាពដើម្បីដាក់ខ្លួនអោយនៅឯកោ (a)<br>3) *ចាំបាច់ធ្វើ:* IHE ធ្វើការជាមួយករណី ដើម្បីកំណត់ទំនាក់ទំនង IHE ជាមួយនឹងការប្រឈម/ប៉ះពាល់<br>4) *ចាំបាច់ធ្វើ:* IHE ជូនដំណឹង* ទំនាក់ទំនងដែលបានកំណត់អត្តសញ្ញាណអំពីការប្រឈម/ប៉ះពាល់ និងណែនាំពួកគេអោយធ្វើចត្តាឡីស័កនៅផ្ទះ និងធ្វើតេស្តរកជំងឺ COVID-19<br>5) *ចាំបាច់ធ្វើ:* IHE ប្រាប់ករណីថា DPH នឹងទាក់ទងជាមួយករណីដោយផ្ទាល់ ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញបទបញ្ជាមន្ត្រីសុខភាពដើម្បីធ្វើចត្តាឡីស័ក (b)<br>6) *ចាំបាច់ធ្វើ:* IHE បញ្ជូនព័ត៌មានទំនាក់ទំនងសម្រាប់ករណី និងទំនាក់ទំនង IHE ដោយប្រើ ប្រើនូវ ករណីជំងឺ COVID-19 និងបញ្ជីខ្សែស្រឡាយទំនាក់ទំនង សម្រាប់វិស័យអប់រំ ហើយផ្ញើទៅ DPH តាមរយៈការផ្ញើអ៊ីម៉ែលទៅកាន់: ACDC-Education@ph.lacounty.gov.<br>7) *ណែនាំអោយធ្វើ:* IHE ធ្វើការជូនដំណឹងទូទៅ* ដើម្បីជូនដំណឹងដល់សហគមន៍សាលារៀនកាន់តែទូលំទូលាយឡើង នៃការប្រឈម/ប៉ះពាល់ និងការប្រុងប្រយ័ត្នដែលត្រូវបានធ្វើ ដើម្បីការពារការរីករាលដាល។<br>*គំរូលិខិតជូនដំណឹងអំពីការប្រឈម/ប៉ះពាល់ និងការជូនដំណឹងទូទៅ មាននៅឯ: គំរូលិខិតជូនដំណឹងសំរាប់គ្រឹះស្ថានអប់រំ អំពីជំងឺ COVID-19។ |
| **2 ករណី** | 1) *ចាំបាច់ធ្វើ:* អនុវត្តតាមជំហ៊ាននានា សម្រាប់ ១ ករណី ដែលបានបញ្ជាក់<br>2) *ណែនាំអោយធ្វើ:* ប្រសិនបើមានករណីកើតឡើងក្នុងរយៈពេល ១៤ ថ្ងៃ ពីគ្នា, IHE នឹងកំណត់ថាតើមានទំនាក់ទំនង ឬតំណភ្ជាប់រោគរាតត្បាត (epi) ដែរឬទេ។* ឧបករណ៍មួយអាចរកបាន ដើម្បីជួយក្នុងការវាយតំលៃ នៃទំនាក់ទំនងរោគរាតត្បាត នៅឯ: សន្លឹកកិច្ចការស៊ើបអង្កេត ការប្រឈម/ប៉ះពាល់ជំងឺ COVID-19 សម្រាប់វិស័យអប់រំ។<br>* មិនមានទំនាក់ទំនង Epi → IHE បន្តការត្រួតពិនិត្យ នូវការប្រឈម/ប៉ះពាល់ជាប្រចាំ។<br>* មានទំនាក់ទំនង Epi → IHE អនុវត្តនីតិវិធានការណ៍ត្រួតពិនិត្យការឆ្លងបន្ថែម។ |

| | |
|---|---|
| **3+**<br>ករណី | *ចាំបាច់ធ្វើ:* ប្រសិនបើមានចង្កោមនៃករណីចំនួនបី ឬច្រើនករណីបានកើតឡើង ក្នុងរយៈពេល ១៤ ថ្ងៃពីគ្នា, សាលារៀនជូនដំណឹង កម្មវិធីត្រួតពិនិត្យជំងឺឆ្លង តាមលេខ ៥៦២.៥៧០.៤៣០២។<br>*ណែនាំអោយធ្វើ:* មុនពេលជូនដំណឹងដល់នាយកដ្ឋានសុខភាពនៃចង្កោមករណី, IHE ប៉ាន់ប្រមាណ ថាតើ មាននូវទំនាក់ទំនង epi សម្រាប់ ≥៣ ករណី។<br>*ចាំបាច់ធ្វើ:* បំពេញឯកសារ [បញ្ជីរាយខ្សែស្រឡាយករណីជំងឺ COVID-19 និងទំនាក់ទំនងសម្រាប់វិស័យអប់រំ]() ដើម្បីកំណត់ថាតើ លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើងត្រូវបានបំពេញ/សមស្រប។<br><br>*លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង <u>មិនត្រូវបានបំពេញ/សមស្រប</u> → សាលារៀនបន្តការត្រួតពិនិត្យការប្រឈម/ប៉ះពាល់ជាប្រចាំ។<br>*លក្ខណៈវិនិច្ឆ័យនៃការផ្ទុះឡើង <u>បានបំពេញ/សមស្រប</u> → កម្មវិធីគ្រប់គ្រងជំងឺឆ្លង និងជួយក្នុងការគ្រប់គ្រងការផ្ទុះឡើង។<br>*ចាំបាច់ធ្វើ:* ក្នុងអំឡុងពេលនៃការស៊ើបអង្កេតនៃការផ្ទុះឡើង, IHE ផ្តល់នូវព័ត៌មានថ្មីៗ/ទាន់សម័យជា ទៀងទាត់ ដល់នាយកដ្ឋានសុខាភិបាល រហូតដល់ការផ្ទុះឡើងត្រូវបានដោះស្រាយ (យ៉ាងហោចណាស់ ១៤ ថ្ងៃ ចាប់តាំងពីករណីដែលបានបញ្ជាក់ចុងក្រោយ)។ |

**(a)** បានប្រសើរឡើង **ហើយ** យ៉ាងហោចណាស់ ១០ ថ្ងៃ បានកន្លងផុតទៅ ចាប់តាំងពីរោគសញ្ញានានា បានលេចចេញ មកជាលើកដំបូង **ឬ**, ប្រសិនបើក្នុងករណីមិនមានរោគសញ្ញាអ្វីនោះទេ, រហូតដល់ ១០ ថ្ងៃបានកន្លងផុតទៅ បន្ទាប់ពីការធ្វើតេស្តឃើញវិជ្ជមាន របស់ពួកគេ។ IHE នឹងផ្តល់ជំនួយដាក់ខ្លួនអោយនៅឯកោ ដល់និស្សិត/មហាវិទ្យាល័យ ប្រសិនបើមានតំរូវការ។

**(b)** បទបញ្ជារបស់មន្ត្រីសុខាភិបាល, ទំនាក់ទំនងត្រូវបានកំណត់អោយធ្វើចត្តាឡីស័ក រយៈពេល ១៤ ថ្ងៃ ចាប់តាំងពីថ្ងៃ នៃការប្រឈម/ប៉ះពាល់ចុងក្រោយ នៅខណៈពេលឆ្លង។ IHE នឹងផ្តល់ជំនួយនៃការធ្វើចត្តាឡីស័ក ដល់និស្សិត/មហាវិទ្យាល័យ ប្រសិនបើមានតំរូវការ។